**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..[illegible].....សហវ.....

ថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មករា ឆ្នាំ២០១៩

**ជម្រាបជូន**

- ឯកឧត្តមអនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិគណនេយ្យ
- ឯកឧត្តមប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម

**កម្មវត្ថុ:** ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩។

**យោង:**-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

-បានឃើញអនុក្រឹត្យលេខ ៤៨៨/អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៥/អនក្រ/បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨/អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៤០/អនក្រ/បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

-បានឃើញប្រកាសលេខ ១៩៤៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញប្រកាសលេខ៧៣៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ៥៤៨ សហវ.អសក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០១៧-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) បានរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ឱ្យក្លាយជាឧបករណ៍គោលនយោបាយដ៏ស័ក្តិសិទ្ធិ សម្រាប់គាំទ្រ និងគាំពារដល់ការកែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបង្កើនល្បឿន ពង្រីកវិសាលភាព និងធ្វើឱ្យកាន់តែស៊ីជម្រៅ សំដៅពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងរដ្ឋបាលឌីជីថល ដែលជាការត្រៀមលក្ខណៈសម្បត្តិដើម្បីប្រើប្រាស់កាលានុវត្តភាព និងឧត្តមភាពប្រៀបធៀបនៃបដិវត្តឧស្សាហកម្មជំនាន់ទី៤ ឱ្យអស់សក្តានុពល ឆ្ពោះទៅសម្រេចគោលដៅក្នុងការដណ្តើមឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏កំពុងតែសស្រាក់សស្រាំបញ្ចប់ការងារដែលសេសសល់ក្នុងដំណាក់កាលទីបី នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដើម្បីឈានចូលដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ប្រកបដោយភាពជឿជាក់ និងដែលគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ២០២៥ ខាងមុខ។

ស្ថិតក្នុងបរិការណ៍នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៩ ដោយធានាឱ្យសេវាសវនកម្មផ្ទៃក្នុងក្លាយឧបករណ៍ត្រួតពិនិត្យកាន់តែមុតស្រួច មានសមត្ថភាពគ្រប់គ្រងហានិភ័យថ្មីៗ និងជួយពង្រឹងបន្ថែមចំពោះប្រព័ន្ធគ្រប់គ្រងចាស់ថ្មី ដែលជាផ្លែផ្កានៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបាញ់ឆ្ពោះទៅរកការពង្រឹងរដ្ឋបាលសាធារណៈរបស់ កសហវ ឱ្យកាន់តែវៃឆ្លាត ស្អាតស្អំ និងមានសមត្ថភាពកាន់តែខ្លាំងពូកែ។ អនុលោមតាមគោលបំណងនេះ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៩ ដែលជាផែនការឆ្នាំទីបីនៃផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០១៧-២០១៩ ត្រូវបានកែតម្រូវដោយផ្តល់ទម្ងន់ទៅលើចំណុចផ្តោត និងគោលដៅសវនកម្មសំខាន់ៗមួយចំនួន ជាអាទិ៍៖ ១. ការកេងបន្លំ ២. ការគ្រប់គ្រងការផ្លាស់ប្តូរ និងវិមជ្ឈការការទទួលខុសត្រូវ ៣. ការគ្រប់គ្រង



ស្រ

សមត្ថភាព និងផលិតភាពមន្ត្រី ៤. គុណភាពសេវាសាធារណៈ ៥.ប្រសិទ្ធភាពការងារត្រួតពិនិត្យ ៦. ការពង្រឹងមូលដ្ឋានទិន្នន័យ ៧. ការពង្រឹងស្វ័យប្រវត្តកម្មការងារ (អេឡិចត្រូនិក និងឌីជីថល) និង៨. អភិបាលកិច្ចល្អ ព្រមទាំងការធ្វើសវនកម្មតាមវិធានជ្រើសរើសលើអង្គភាពដែលមានថវិកាជាឧបសម្ព័ន្ធរបស់ កសហវ និងមន្ត្រីនៃ កសហវ មួយចំនួន ដែលបំពេញការងារនៅក្រៅទីតាំងរបស់ កសហវ ដូចជាក្នុងគណៈកម្មាធិការ ក្រុមប្រឹក្សាភិបាល ក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ ក្រុមការងារអន្តរក្រសួងជាដើម។

ជាលទ្ធផលក្រោយការកែតម្រូវ ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩ បានកំណត់វិសាលភាពសវនកម្មសម្រាប់ថ្នាក់កណ្តាលមានចំនួន១២ គោលដៅ ក្នុងនោះអគ្គនាយកដ្ឋានមានចំនួន៩ អង្គភាពមានចំនួន២ (ក្រុមប្រឹក្សានីតិកម្ម និងក្រុមប្រឹក្សាជាតិគណនេយ្យ) និងការងារ FMIS តាមក្រសួង ស្ថាប័នមានចំនួន០១ គោលដៅ ព្រមទាំងតាមអង្គភាពក្រោមឱវាទ កសហវ ថ្នាក់រាជធានី-ខេត្ត ទាំង២៥ (ដូចមានបង្ហាញក្នុងផែនការភ្ជាប់មកជាមួយ)។ ជាមួយគ្នានេះ ការងារត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពការកែលម្អតាមអនុសាសន៍សវនកម្មដោយឡែក ក៏ត្រូវបានកំណត់នៅអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលផងដែរ។

ដូច្នេះ ដើម្បីធានាឱ្យផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩ អាចសម្រេចបានតាមគោលបំណង ក្នុងវិសាលភាពសវនកម្មខាងលើប្រកបដោយលទ្ធផលល្អប្រសើរ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវខិតខំអនុវត្តភារកិច្ច ដោយអនុលោមតាមអភិក្រមការងារទាំងបួនប្រការរបស់ កសហវ តាមស្តង់ដានិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនករផ្ទៃក្នុង និងទទួលបាននូវសិទ្ធិចូលដល់ប្រព័ន្ធ មន្ត្រី បញ្ជិកា ស្ថិតិ ឯកសារ ទ្រព្យសម្បត្តិ គណនី និងអាចផ្ទៀងផ្ទាត់ជាក់ស្តែងដល់ទីកន្លែងស្របតាមនីតិវិធីសវនកម្មស្តង់ដា។ ទន្ទឹមនឹងនេះ សវនដ្ឋាន (អង្គភាពរងសវនកម្ម) ទាំងអស់ ត្រូវបង្កលក្ខណៈងាយស្រួលនិងផ្តល់កិច្ចសហការជិតស្និទ្ធ ក្នុងការជួបពិភាក្សានិងផ្តល់ព័ត៌មាន (វីង/ទន់) ដោយសុឆន្ទៈ ប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។ ប្រធានសវនដ្ឋានត្រូវខិតខំផ្តល់ការបំភ្លឺរាល់ចំណុចកត់សម្គាល់ដោយសវនករ ឱ្យបានទាន់ពេលវេលាស្នើសុំ និងត្រូវចូលរួមក្នុងអង្គប្រជុំសវនកម្មបើកនិងបិទ ដើម្បីក្តាប់បាននូវនីតិវិធី សំណូមពរ និងលទ្ធផលសវនកម្មដោយផ្ទាល់។

បន្ថែមលើនេះ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងអាចចុះសវនកម្មដោយឡែក តាមការសម្រេចរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃ កសហវ លើពាក្យបណ្តឹង លើសំណើរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងលើសំណូមពររបស់អង្គភាពក្រោមឱវាទ កសហវ ក្រៅពីការធ្វើសវនកម្មតាមផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩ នេះ។ ការចុះអនុវត្តសវនកម្មអាចប្រព្រឹត្តទៅដោយផ្តល់ព័ត៌មានជាមុន និងមិនផ្តល់ជាមុនតាមការចាំបាច់។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩ នេះ ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន:

- អាជ្ញាធរសវនកម្មជាតិ "ដើម្បីជូនជ្រាប"
- សវនដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ